**សកម្មភាព** ៖ **ល្បែងអានសៀវភៅ**

**ភាសាខ្មែរ**

ការស្តាប់ (ស្តាប់គេនិយាយ និងមានសមត្ថភាពស្តាប់ដោយធ្វើតាមការណែនាំងាយៗ)។

ប្រើពាក្យសម្តីកាយវិការ និងនិមិត្តសញ្ញាដើម្បីទំនាក់ទំនង

(ទំនាក់ទំនងដោយប្រើពាក្យសម្តី)។

**គោលបំណង**

**(ភាសាខ្មែរ)** ប្រាប់បានខ្លះៗពីដំណើររឿងតាមរយៈរូបភាពដែលបានបង្ហាញ។

ប្រាប់ឡើងវិញពីសកម្មភាពតាមដំណាក់កាល ដោយអនុវត្តតាមដំណាក់កាលណែនាំ។

ប្រាប់ចំណងជើងរឿង និងអត្ថន័យតាមរូបភាព។ និទានរឿងតាមរូបភាពស្តាប់។

**សៀវភៅ** ៖ ដកស្រង់ចេញពីរឿង "បិសាចចម្លែកតូចៗ" ។

**កម្រិត** ៖ មធ្យម ទាប ខ្ពស់

**រយៈពេល** ៖ ៣០ នាទី

**ឧបករណ៍** ៖ សៀវភៅរឿង "បិសាចចម្លែកតូចៗ" ។ ឱ្យក្មេងៗឆ្លើយម្នាក់ ១ពាក្យ។

-តើអ្វីដែលចូលក្នុងខ្លួនហើយធ្វើឱ្យកូនៗឈឺ? គឺមេរោគ។

-តើមេរោគមាននៅកន្លែងណាខ្លះ? មាននៅកន្លែងទាំងអស់។

-តើយើងអាចមើលមេរោគដោយភ្នែកទទេបានដែរឬទេ? មិនបានទេ។

-តើយើងកំចាត់មេរោគដោយរបៀបណា? គឺត្រូវអនាម័យជានិច្ច។

-តើកូនៗត្រូវធ្វើដូចម្តេចពេលក្អក កណ្តាស់ និងហៀរសំបោរ?

យកដៃខ្ទប់មាត់ ច្រមុះ និងជូតសំបោរឱ្យបានស្អាត។

-តើយើងត្រូវមានទម្លាប់អនាម័យល្អអ្វីខ្លះ?

លាងសម្អាតដៃមុន និងពេលញ៉ាំអាហារ ចេញពីបន្ទប់ទឹក និងសម្អាតខ្លួនប្រាណ។

**ការរៀបចំ** ៖ អានសៀវភៅរឿងឱ្យបានច្រើនដងមុខនឹងលេង។ សរសេរសំណួរដែលត្រូវសួរក្មេងៗ នៅខាងខ្នងសៀវភៅឬ អ្នកអាចបង្កើតជាសំណួរដោយផ្ទាល់ក៏បានដែរ។

**សេក្តីណែនាំ៖**

1. ថ្ងៃនេះអ្នកគ្រូនឹងអានសៀវភៅរឿង "បិសាចចម្លែកតូចៗ" ឱ្យកូនៗស្តាប់ទាំងអស់គ្នា។

2. បង្ហាញសៀវភៅរឿង “បិសាចចម្លែកតូចៗ” ទៅកាន់ក្មេងៗទាំងអស់គ្នា។

3. ឱ្យក្មេងៗនិយាយពាក្យថា ‹‹សៀវភៅ›។

4. បង្ហាញពីរបៀបនៃការកាន់ និងថែទាំសៀវភៅ។ ឧទាហរណ៍៖ កុំបត់សៀវភៅទៅក្រោយ កុំហែក សន្លឹកសៀវភៅឬកុំគូរវាសផ្តេសផ្តាសលើសៀវភៅ(ការគូររូបលើសៀវភៅគឺសម្រាប់តែសៀវភៅ ផាត់ពណ៌ ឬ សៀវភៅគូររូបប៉ុណ្ណោះ)។

5. បង្ហាញក្របសៀវភៅទៅកាន់ក្មេងៗ ហើយពន្យល់អំពីចំណងជើងរឿង ។

6. ឱ្យក្មេងៗទាំងអស់ថាតាម ចំណងជើងរឿង “បិសាចចម្លែកតូចៗ” ។

7. អានសៀវភៅរឿងចាប់ពីទំព័រដើមរហូតដល់ចប់យឺតៗ ដោយបង្ហាញរូបភាពក្នុងទំព័រនីមួយៗ។

8. បង្ហាញរូបភាពម្តងទៀត និងនិយាយពីរូបភាព នៅក្នុងសៀវភៅ។

9. សួរក្មេងៗអំពីសំណួរដែលអ្នកបានត្រៀមទុក ។

   -តើអ្វីដែលចូលក្នុងខ្លួនហើយធ្វើឱ្យកូនៗឈឺ? គឺមេរោគ។

   -តើមេរោគមាននៅកន្លែងណាខ្លះ? មាននៅកន្លែងទាំងអស់។

   -តើយើងអាចមើលមេរោគដោយភ្នែកទទេបានដែរឬទេ? មិនបានទេ។

   -តើយើងកំចាត់មេរោគដោយរបៀបណា? គឺត្រូវអនាម័យជានិច្ច។

   -តើយើងត្រូវធ្វើដូចម្តេចពេលក្អក កណ្តាស់ និងហៀរសំបោរ?

   យកដៃខ្ទប់មាត់ ច្រមុះ និងជូតសំបោរឱ្យបានស្អាត។

   -តើយើងត្រូវមានទម្លាប់អនាម័យល្អអ្វីខ្លះ?

   លាងសម្អាតដៃមុន និងពេលញ៉ាំអាហារ ចេញពីបន្ទប់ទឹក និងសម្អាតខ្លួនប្រាណ។

10. ឆ្លើយសំណួរខ្លះៗដែលក្មេងមិនយល់ និងពន្យល់បន្ថែមទៀត ប្រសិនបើពួកគេមិនទាន់យល់ច្បាស់ ជាការស្រេច។